# ២៨- អ្នកតាព័ន្ធសាឡី

ប្រជុំរឿងព្រេងខ្មែរភាគ ៨ ពីទំព័រទី ១៩៨ – ២០៣

---

អ្នកតាព័ន្ធសាឡី ស្ថិតនៅចុងជីដុះ លូតចូលទៅក្នុងព្រៃកខាងជើងកំពង់ស្នេហ៍ ចម្ងាយប្រមាណ ៩គម. ពីភូមិទ័ពស្ដេច នៅក្នុងឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង ។ ផ្ទៃដីដែលជាកន្លែងអ្នកតានេះ ប្រមាណជា ៣០០ម. X ១.០០០ម. សុទ្ធសឹងជាគ្រោកនិងព្រៃរនាមពាសពេញ ។

អ្នកតា ព័ន្ធសាឡី នេះ អ្នកស្រុកមិនដែលហៅថា "អ្នកតា" ទេ គេហៅថា "អស់លោកព័ន្ធសាឡី" ។ ពាក្យថា "អ្នកតា" និង "អស់លោក" សឹងមានន័យព្រលាំគ្នា ប៉ុន្តែពាក្យថា "អស់លោក" គេច្រើនហៅចំពោះអ្នកតា ឬបង់បត់ណា ដែលមានឥទ្ធិពលខ្លាំងពូកែ ហើយចេះរក្សានូវពាក្យសត្យ គួរឲ្យមនុស្សលោកគោរពបូជា។ ដូច្នេះ ពាក្យថា "អស់លោក" គឺជាពាក្យខ្ពស់ជាងពាក្យថា "អ្នកតា" ។

អ្នកតានេះ មានខ្ទមសង់ដោយឈើ ប្រក់ក្បឿង នៅក្រោមដើមឈើមួយ ។ នៅក្នុងខ្ទមគ្មានរូបសំណាកអ្វីជាពិសេសទេ មានតែថ្មពីរដុំ ទំហំល្មមលើកម្នាក់រួចប៉ុណ្ណោះ ប៉ុន្តែសព្វថ្ងៃនេះ ដុំថ្មនោះក៏បែកបាក់ជាច្រើនបំណែកទៅហើយ ។

## ប្រវត្តិអ្នកតា

កាលពីសម័យមុនយូរមកហើយនោះ ត្រង់កន្លែងអ្នកតានេះ មានដើមសាលី2ប្រាំមួយដើម ដើមស្វាយមួយដើម និងព្រៃរនាមដុះព័ទ្ធជុំវិញដីទួលមួយ ទំហំប្រមាណជា ១០ម. បួនជ្រុងស្មើរបៀបដូចបន្ទាយ ។ កន្លែងនេះកម្រមានអ្នកណាមួយ ហ៊ានរុករកវល្លិ ឬ កាប់ឧសដុតណាស់ សូម្បីតែដើរកាត់ក៏គ្មានអ្នកណាហ៊ានដែរ ព្រោះជាជម្រកសត្វសាហាវមានខ្លា ពស់ និងជ្រូកព្រៃជាដើម ។ ចំណេរមកខាងក្រោយ មានមនុស្សម្នាក់ឈ្មោះ ស្រឹង មិនដឹងជាមកពីស្រុកណាទេ គាត់នោះមានមាឌធំជំបង សក់រួញ ជាអ្នកក្លាហានក្នុងរឿងកាប់ចាក់ ប្រពន្ធឈ្មោះនាង សុវណ្ណពាសវាល ដែលមានមាឌធំ ប្រដំត្រសងគ្នានឹងគាត់ដែរ ហើយប្រកបដោយរូបសម្បត្តិយ៉ាងស្រស់ផង ។ ទាំងពីរនាក់ប្ដីប្រពន្ធនេះបានមកតាំងលំនៅៗលើដីទួល ក្នុងចន្លោះដើមសាលីទាំងប្រាំមួយដើមនោះ ។ គាត់បានកាប់ឆ្ការព្រៃ ធ្វើផ្លូវសម្រាប់ចេញចូល ។ អ្នកស្រុកផងទាំងពួងមិនដឹងថាគាត់ប្រកបរបររកស៊ីអ្វីទេ ព្រោះគេឃើញមកនៅទីនោះតែ ៨ ឬ ១០ថ្ងៃប៉ុណ្ណោះ ហើយមិនជាទៅណាបាត់ ។ លុះ៩- ១០ថ្ងៃក្រោយមក ទើបឃើញគាត់នៅទីនោះដដែលវិញ បាត់ឃើញៗ តែរបៀបនេះរវាងជាង ១ឆ្នាំទើបបាត់លែងឃើញគាត់ទាំងពីរនាក់ប្ដីប្រពន្ធរហូតតែម្ដង ។

ម្យ៉ាងទៀត ក្នុងសម័យនោះអ្នកស្រុកជិតខាងទាំងប៉ុន្មាន ឲ្យតែឃើញមានមនុស្សណាបែបអង់អាចក្លាហានហើយមានមាឌមាំៗ ធំៗ មិនហ៊ាននិយាយស្ដីសួរនាំអ្វីទេ ។ ឯសត្វសាហាវទាំងឡាយដែលនៅក្នុងព្រៃនោះ

ទៀតសោត ក៏មិនមកបៀតបៀនដល់រូបគាត់ទាំងពីរនាក់ប្ដីប្រពន្ធនោះដែរ ហេតុដូច្នេះ ទើបអ្នកស្រុកម្ដុំនោះកោតខ្លាចគាត់តែរៀងៗខ្លួន ។ ម្យ៉ាងទៀត បុរសស្រឹង ចេះយកចិត្តទុកដាក់នឹងអ្នកស្រុក ជួយសង្គ្រោះអ្នកជិតខាងជាច្រើន ដូចជាមានពស់ចឹក ឬ ឈឺអ្វីផ្សេងៗ គាត់តែងតែជួយឥតរើសមុខ នៅពេលដែលគាត់ដើរទៅប្រទះ ឬ គេរត់ទៅពឹងពាក់គាត់ ។

ក្រោយពេលដែលបាត់លែងឃើញគាត់ ចំនួន ២-៣ ឆ្នាំមក សត្វសាហាវដែលនៅក្នុងព្រៃនោះទាំងប៉ុន្មានខ្លះក៏គេចខ្លួនបាត់ ខ្លះនៅទីនោះដដែល ប៉ុន្តែបែរជាស្លូតបូតទៅវិញ ដោយហេតុនេះហើយ ទើបអ្នកភូមិជិតខាងហ៊ានបបួលគ្នាទៅមើលកន្លែងនោះ ។ លុះចូលទៅដល់ ហើយគ្មានឃើញអ្វីទាំងអស់ ឃើញតែថ្ម ២ដុំមានទំហំល្មមលើកម្នាក់រួច នៅទន្ទឹមគ្នាទៀបគល់ឈើមួយ (មិនជាដើមអ្វី អ្នកឲ្យការណ៍មិនបានបញ្ជាក់) នឹងដានជើងសត្វតូច ធំជាច្រើន ។ រូបតា ស្រឹង និងប្រពន្ធគាត់ ដែលកាលពីមុន អ្នកខ្លះសន្និដ្ឋានថាស្លាប់ អ្នកខ្លះថាគាត់វិលទៅស្រុកកំណើតគាត់វិញនោះ ក្នុងពេលនោះក៏ជឿថា ពិតជាស្លាប់តែម្ដង ។ ឯថ្ម ២ដុំនេះគឺក្លាយមកពីរូបយាយនិងតានោះឯង ។ អ្នកស្រុកនាំគ្នាគោរពបូជា ថ្វាយផ្លែឈើនំចំណីផ្សេងៗ និងធ្វើខ្ទមប្រក់ស្លឹកតូចល្មម ដាក់ដុំថ្មទាំងពីរនោះទៅ រួចហើយនាំគ្នាបន់ស្រន់ សុំសេចក្ដី សេចក្ដីចម្រើន ។ តមកខាងក្រោយ ដោយឃើញដីម្ដុំនោះមានជីជាតិល្អ អ្នកស្រុកក៏នាំគ្នាកាប់ឆ្ការព្រៃ នៅជិតខាងអ្នកតានោះធ្វើស្រែអស់ទៅ នៅសល់តែគ្រោកបន្តិចបន្តួចប៉ុណ្ណោះ ។

រីឯអ្នកស្រុកដែលទៅប្រកបរបរស្រែ នៅក្បែរៗអ្នកតានោះតែងតែមានប្រទាស់ដាក់ម្ហូបចំណី បាយដំណើបនំកូនត្រី កូនខោអាវ កូនក្រមា យកទៅដោតតាមភ្លឺស្រែ ឬយកទៅថ្វាយផ្ទាល់ចំពោះអ្នកតាគ្រប់ៗគ្នា បើមិនបានធ្វើរបៀបនេះទេ នឹងពុំសូវបានសេចក្ដីសុខក្នុងការធ្វើស្រែឡើយ ។

## អំពីឥទ្ធិពល

ពីដើមអស់លោកនេះ អ្នកខ្លះហៅថាអស់លោក "ចុងគ្រោក" មានរក្សានូវវត្ថុប្រើប្រាស់ជាច្រើនដូចជា ចានក្បាន តូច- ធំជាដើម ។ល។ វត្ថុទាំងនោះ បើអ្នកស្រុកត្រូវការខ្ចីយកទៅប្រើប្រាស់ ក្នុងកិច្ចរវល់ផ្សេងៗមានរៀបមង្គលការ កូនប្រុសស្រី ជាដើម អាចទៅពឹងរូបសម្នឹងឲ្យខ្ចីបានដូចប្រាថ្នា ។ ប៉ុន្តែរយៈពេលដែលអាចខ្ចីបាននេះ គឺមានត្រឹមតែ ៤-៥ឆ្នាំ ប៉ុណ្ណោះ ក៏សាបរលាបវិញអស់ទៅ ដោយហេតុអ្នកខ្ចីយកទៅប្រើ ចេះតែធ្វើឲ្យបាក់បែកបាត់ មិនទិញដាក់សងវិញ ហើយយកទៅសងមិនដែលគ្រប់ចំនួន ។

ឯសត្វព្រៃដែលអស់លោករក្សាគឺ ខ្លា ពស់ ជ្រូកព្រៃ រមាំង និងក្រពើ ។ អ្នកស្រុកមិនសូវដែលបានឃើញគ្រប់គ្នាទេ ហើយសត្វទាំងនោះ ក៏មិនដែលបៀតបៀនមនុស្សផង វៀរលែងតែអ្នកមាត់អាក្រក់ អ្នកតានឹងធ្វើឲ្យមានភ័យភិតជាមិនខាន ។ សត្វទាំងនោះ បើលេងភ្លេងថ្វាយហើយសុំមើល នឹងបានឃើញដូចសេចក្ដីប្រាថ្នា ។ ចំណែកឯរមាំង លោកគ្មានលាក់លៀមអ្វីទេ គឺវាដើររកស៊ីពេញតែព្រៃនោះ តែបើយើងចង់ដេញ ឬ បាញ់ត្រូវសុំអស់លោកសិន ទើបបាញ់បាន បើមិនសុំទេ ទោះបីខំដេញ ឬ បាញ់យ៉ាងណាក៏មិនបានដែរ ។

## ការសម្ដែងឫទ្ធិនៃអ្នកតានោះ

រាល់ថ្ងៃពេញបូណ៌មី និងថ្ងៃខែដាច់ នាពាត្រីកាល មានភ្លើងភ្លឺព្រោងព្រាតពេញអាស្រម និងនៅទីជិតៗអាស្រមនោះ ភ្លើងនេះនរណាក៏មើលឃើញដែរ ។ ដោយពេលវេលាកន្លងទៅជាយូរយារណាស់ពេកមនុស្សដែលធ្លាប់ជឿហើយគោរពបូជាអ្នកតានោះ ក៏ស្លាប់អស់ទៅក្មេងៗជាន់ក្រោយមិនសូវជឿមិនសូវគោរពបូជា ឥទ្ធិពលអ្នកតាក៏ថយចុះបន្តិចម្តងៗជាលំដាប់រហូតមក ។

## ឥទ្ធិពលដែលមាននៅខ្លះសព្វថ្ងៃ

តាំងពីឆ្នាំ ១៩៤០ មក អស់លោកនោះបានមកសណ្ឋិតលើរូបលោកយាយម្នាក់ឈ្មោះ ធាយ អាយុ ៦០ឆ្នាំ (គិតមកទល់នឹងឆ្នាំ ១៩៦៦) នៅភូមិទ័ពស្តេច គាត់ធ្លាប់កាន់ទំនៀមឡើងអ្នកតា ដារថ្វាយអ្នកតានេះយ៉ាងជាប់លាប់ណាស់ គាត់តែងមេផ្តើមធ្វើរៀងរាល់ឆ្នាំ បើមិនបានធ្វើទេ អ្នកស្រុកមុខជាពុំសូវបានសុខសប្បាយឡើយ ។ ចំណែកអ្នកដែលត្រូវទៅធ្វើស្រែប្រាំងនៅកន្លែងនោះ ត្រូវតែរៀបគ្រឿងបូជាឲ្យមានសព្វគ្រប់ដូចពីដើមទើបបាន ។ ឯអ្នកឃ្វាលគោ ក្របី ត្រូវកាន់ត្រណមឲ្យជាប់ និយាយលេងសើចផ្តេសផ្តាសនូវពាក្យអាក្រក់ ឬ ជេរគ្នាជាដើម មិនបានជាដាច់ខាត អ្នកតានិងឲ្យពស់ដេញ ឬ វង្វេងផ្លូវមិនខាន ។

សព្វថ្ងៃគេនៅប្រយ័ត្នមាត់កនៅឡើយ នៅពេលដើរកាត់ព្រៃនោះ ។ ម៉្យាងទៀត បើមាននំចំណី ឬ បាយទឹកយកទៅទទួលទាននៅក្បែរនោះ ហើយមិនបានថ្វាយបន្តិចបន្តួចទេ អ្នកតានឹងធ្វើឲ្យចុកពោះ ឈឺក្បាល វិលមុខមិនខាន ។ បើឈឺហើយលុះតែទៅនិយាយបន់ស្រន់ អុជទៀនធូបនៅឯផ្ទះសម្នឹង ហើយនិយាយអង្វរករឲ្យជួយសង្គ្រោះអ្នកដែលឈឺនោះ ដោយទទួលនូវកំហុសដែលខ្លួនបានធ្វើ ហើយសន្យាថានឹងលេងប្រព្រឹត្តឲ្យខុសទៀតទើបជា ។

នៅពេលមានអាសន្នដូច្នេះ គេឥតប្រើភ្លេងទេ គ្រាន់តែអុជទៀនធូប និយាយបែរបន់អ្នកសម្នឹងទៅជាការស្រេច ។ ឯខ្ទមអ្នកតា កាលណាបើមានបាក់បែក ត្រូវតែនាំគ្នាសង់ឡើងវិញ បើមិនធ្វើនឹងមានភ័យមិនខាននេះចំពោះតែអ្នកភូមិនៅជិតខាងដូចជាភូមិទ័ពស្តេចប៉ាទិ្វប និងភូមិកំពែងស្នេហ៍។